# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ២៩៨.ថទ.៤១-៩៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោក ប្រធានតុលាការកំពូល**

**លោក ប្រធានសាលាឧទ្ធរណ៍**

**លោក ប្រធានតុលាការខេត្ត ក្រុង**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីការផ្ញើសេចក្តីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរមកការិយាល័យបញ្ជីថ្កោលទោស ។
**<u>យោង:</u>** លិខិតលេខ ១៣៥២ រប-៩៦ ចុះថ្ងៃទី០២-១២-៩៦ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌បានធ្វើលិខិតដូចមានយោងខាងលើ ទៅលោកប្រធានតុលាការគ្រប់ជាន់ថ្នាក់អោយផ្ញើសេចក្តីចម្លងសាលក្រម និងសាលដីការព្រហ្មទណ្ឌស្ថាពរមកការិយាល័យបញ្ជីថ្កោលទោសអោយបានទៀតទាត់ ចាប់ពីថ្ងៃទី០១ មករា ១៩៩៧ មកដោយបញ្ឈប់អោយធ្វើបញ្ជីសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរតទៅទៀត ។

ឆ្លើយតបនឹងលិខិតរបស់ក្រសួង តុលាការភាគច្រើនបានផ្ញើសេចក្តីចម្លងសាលក្រម និងសាលដីការព្រហ្មទណ្ឌស្ថាពរមកការិយាល័យថ្កោលទោស តាមការគតកំណត់ប៉ុន្តែតុលាការខ្លះទៀតពុំទាន់បានផ្ញើមកទេ។ រីឯតុលាការមួយចំនួនតូចទៀត នៅតែបន្តផ្ញើបញ្ជីតាមគំរូជាតារាងរបៀបចាស់ ដែលក្រសួងបានបញ្ឈប់លែងអោយធ្វើទៅហើយនោះដដែល ។

ខ្ញុំសូមរំលឹកដល់លោកប្រធានថា ចំពោះតុលាការណាដែលពុំទាន់បានអនុវត្តតាមការណែនរបស់ក្រសួងនេះទេសូមលោកប្រធានយកចិត្តទុកដាក់អនុវត្តអោយបានហ្មត់ចត់ ផ្ញើសេចក្តីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរមកការិយាល័យថ្កោលទោសអោយបានទៀងទាត់ កុំទុកពន្យាពេលឡើយ គឺសាលក្រមនិងសាលដីកាព្រហ្មទណ្ឌណាចូលជាស្ថាពរហើយ ត្រូវតែផ្ញើសេចក្តីចម្លងសាលក្រមនិងសាលដីកាព្រហ្មទណ្ឌស្ថាពរនោះផ្ញើទៅការិយាល័យថ្កោលទោសភ្លាម ដើម្បីក្រសួងចេញលិខិតថ្កោលទោសអោយប្រជាពលរដ្ឋប្រើប្រាស់អោយបានត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមផ្លូវច្បាប់ ម៉្យាងទៀតដើម្បីចៀសវាងការខ្វះខាតនូវលក្ខណៈសម្បត្តិរបស់សេចក្តីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរសម្រាប់ធ្វើលិខិតថ្កោលទោសនេះ សូមលោកប្រធានជួយកំណត់អោយបានច្បាប់សាលអំពីសាវតាជាតិរបស់ទណ្ឌិត និងទោសដែលត្រូវផ្តន្ទាលើទណ្ឌិត ។

សាវតាជាតិរបស់ទណ្ឌិត ត្រូវយកចិត្តទុកដាក់បញ្ជាក់អោយមានច្បាស់លាស់គឺ:

១-នាមត្រកូល និងនាមខ្លួនរបស់ទណ្ឌិត ដែលត្រូវសរសេរអោយបានច្បាស់លាស់ជាទីបំផុត

២-សញ្ជាតិ

៣-ភេទ សំណូមពរសុំកុំប្រើពាក្យ នាង នៅពីមុខឈ្មោះទណ្ឌិត បើជានារីភេទ សូមកំណត់ថា ភេទស្រី ដើម្បីចៀសវាងការភន្តច្រឡំ នឹងឈ្មោះទណ្ឌិតដែលមានត្រកូល នាង

៤-ថ្ងៃខែឆ្នាំ និង ទីកន្លែងប្រព្រឹត្តបទល្មើសនិងថ្ងៃខែឆ្នាំចាប់ឃុំខ្លួនព្រមទាំងបទល្មើស

៥-ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត ឬអាយុ

៦-ឈ្មោះឪពុកនិងម្តាយរបស់ទណ្ឌិត

៧-ឈ្មោះប្រពន្ធឬប្តីរបស់ទណ្ឌិត " ប្រសិនបើមាន " ឬនៅលីវ

៨-ទីលំនៅបច្ចុប្បន្នមុនពេលចាប់ឃុំខ្លួន

ដោយឡែកចំពោះទណ្ឌកម្មដែលត្រូវតុលាការសម្រេចផ្តន្ទាទោសលើទណ្ឌិត សូមសរសេរអោយបានច្បាស់លាស់ជាទីបំផុតផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកប្រធានជួយចាត់ការកិច្ចការនេះអោយល្អប្រសើរនឹងទៀតទាត់តាមការណែនាំរបស់ក្រសួង ដើម្បីក្រសួងចេញលិខិតថ្កោលទោសអោយបានត្រឹមត្រូវនិងមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ ។

ឆ្លៀតឱកាសនេះ ក្រសួងសូមសរសើរដោយស្មោះចំពោះលោកប្រធានតុលាការដែលបានយកចិត្តទុកដាក់អនុវត្តការងារនេះបានល្អប្រសើរនិងទៀតទាត់តាមការកំណត់របស់ក្រសួង។

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**